វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ព្រះរាជក្រម/០៣នស/០៥សីហា១៩៩៤

អនុម័តដោយរដ្ឋសភា ០៤ សីហា ១៩៩៤

# ច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា

## ជំពូកទី ១: បទបញ្ញត្តិទូទៅ

មាត្រា១:

ច្បាប់នេះមានវិសាលភាព គ្របដណ្តប់លើការវិនិយោគនានា ដែលអនុវត្តនៅលើទឹកដី នៃ ព្រះរាជាណាចក្រកម្ពុជា ដោយអ្នកវិនិយោគជាជនជាតិខ្មែរនិង / ឬ ជនបរទេស ។

មាត្រា២:

អ្នកវិនិយោគទាំងអស់ ត្រូវស្ថិតនៅក្រោមច្បាប់នេះ ហើយអាចជារូបវន្តបុគ្គល ឬ ជានីតិ បុគ្គល ។

## ជំពូកទី ២: ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

មាត្រា៣:

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាអង្គការមានសមត្ថកិច្ច និង ជាច្រកចេញចូលតែមួយគត់ ក្នុងការទទួលបន្ទុកការងារនីតិសម្បទា អភិវឌ្ឍន៍ និង ការវិនិយោគ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការពិនិត្យ និង សំរេចការងារនីតិសម្បទា និងអភិវឌ្ឍន៍ និង ការវិនិយោគនានា។

មាត្រា៤:

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានគណៈកម្មាធិការពីរសំរាប់ជំនួយការគឺ :

១- គណៈកម្មាធិការនីតិសម្បទា និង អភិវឌ្ឍន៍

២- គណៈកម្មាធិការវិនិយោគកម្ពុជា ។

មាត្រា៥:

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី ៣: នីតិវិធីនៃការវិនិយោគ

មាត្រា៦:

អ្នកវិនិយោគ ត្រូវដាក់ពាក្យសុំនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាពិនិត្យ និង សំរេច ។

មាត្រា៧:

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវឆ្លើយតបអំពីការសំរេចរបស់ខ្លួនទៅអ្នកវិនិយោគក្នុងរយៈពេល ៤៥ ថ្ងៃយ៉ាងយូរ គិតពីថ្ងៃទទួលពាក្យសុំដែលបានបំពេញបែបបទត្រឹមត្រូវ និងគ្រប់គ្រាន់ ។ បើគ្មានមូលហេតុត្រឹមត្រូវ មន្ត្រីរាជការណាដែលប្រកែកមិនព្រមទទួលពិនិត្យ និងឆ្លើយតប អំពីការសំរេចរបស់ខ្លួន ទៅអ្នកវិនិយោគវិញ ហួសកាលកំណត់ខាងលើ ត្រូវផ្តន្ទាទោសតាមបញ្ញត្តិច្បាប់ ។

## ជំពូកទី ៤: ការធានាលើការវិនិយោគ

មាត្រា៨:

អ្នកវិនិយោគ ត្រូវបានទទួលស្គាល់ និង ចាត់ទុកដោយស្មើភាពគ្នាចំពោះមុខច្បាប់ គ្មានការរើសអើងអំពីសញ្ជាតិ ឬពូជសាសន៍ទេ លើកលែងតែចំពោះកម្មសិទ្ធិលើដីធ្លី ដូចដែលមានចែងក្នុង បទបញ្ញត្តិ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា៩:

រាជរដ្ឋាភិបាលនឹងមិនធ្វើជាតូបនីយកម្មដែលនាំអោយប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់អ្នកវិនិយោគក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

មាត្រា១០:

រាជរដ្ឋាភិបាល មិនត្រួតពិនិត្យលើថ្លៃផលិតផល ឬថ្លៃសេវានានារបស់អ្នកវិនិយោគដែលបានទទួលការអនុញ្ញាតរួចហើយនោះឡើយ ។

មាត្រា១១:

ដោយអនុលោមទៅតាមច្បាប់ទាំងឡាយដែលពាក់ព័ន្ធ ព្រមទាំងបទបញ្ញត្តិទាំងឡាយដែលបានកំណត់ និង ប្រកាសផ្សាយដោយធនាគារជាតិកម្ពុជា រាជរដ្ឋាភិបាលអនុញ្ញាតដល់អ្នកវិនិយោគ មានសិទ្ធិទិញរូបិយប័ណ្ណបរទេស តាមរយៈប្រព័ន្ធធនាគារ សំរាប់បង្វិលទៅបរទេសវិញ ដើម្បីទូទាត់កាតព្វកិច្ចខាងហិរញ្ញវត្ថុ ដែលពាក់ព័ន្ធនឹងការវិនិយោគរបស់ខ្លួន ។

ការទូទាត់ខាងលើនេះរួមមាន :

១- ការទូទាត់លើការនាំចូល និង ការបង្វិលទៅក្រៅប្រទេសទាំងដើមទាំងការ នូវប្រាក់ចងការ ។

២- ការទូទាត់ចំណាយសួយសារ និង ថ្លៃសេវាគ្រប់គ្រង ។

៣- ការផ្ទេរប្រាក់ចំណេញ ។

៤- ការបង្វិលដើមទុនវិនិយោគ ទៅក្រៅប្រទេសវិញ ដូចមានចែងក្នុងជំពូកទី ៨ ។

## ជំពូកទី ៥: ការលើកទឹកចិត្តវិនិយោគ

មាត្រា១២:

រាជរដ្ឋាភិបាល លើកទឹកចិត្ត ដើម្បីជំរុញការវិនិយោគ លើវិស័យសំខាន់ៗ ដូចតទៅ :

១- ឧស្សាហកម្មនាំមុខ ឬ ឧស្សាហកម្មដែលមានបច្ចេកវិទ្យាខ្ពស់

២- ការបង្កើតការងារ

៣- ការបង្កើនការនាំចេញ

៤- ឧស្សាហកម្មទេសចរណ៍

៥- ការផលិតទំនិញកសិ-ឧស្សាហកម្ម និង ឧស្សាហកម្មកែច្នៃ

៦- ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ការផលិតថាមពល

៧- អភិវឌ្ឍន៍ខេត្ត និង ជនបទ

៨- ការការពារបរិដ្ឋាន

៩- ការវិនិយោគក្នុងតំបន់អភិវឌ្ឍន៍ពិសេស ដែលនឹងត្រូវបង្កើតឡើងដោយច្បាប់ ។

មាត្រា១៣:

ការលើកទឹកចិត្ត មានការលើកលែងទាំងស្រុង ឬ មួយផ្នែក នៃពន្ធគយ និង ពន្ធអាករ ។

មាត្រា១៤:

ការលើកទឹកចិត្តទាំងឡាយ រួមមានដូចខាងក្រោមនេះ:

១- អត្រាពន្ធលើប្រាក់ចំណេញសុទ្ធ ៩% លើកលែងតែអត្រាពន្ធផ្សេងៗ លើការរុករក និងអាជីវកម្ម ធនធានធម្មជាតិ ព្រៃឈើ ប្រេងកាត រ៉ែ មាស ត្បូងថ្មមានតម្លៃ ។ល។ ដែលត្រូវចែងក្នុងច្បាប់ដោយ ឡែក ។

២- ពន្ធលើប្រាក់ចំណេញ អាចលើកលែងបានរហូតដល់រយៈពេល ៨ឆ្នាំ គឺអាស្រ័យលើលក្ខណៈសម្បត្តិរបស់ការវិនិយោគ នីមួយៗ និង អាទិភាពដែលរាជរដ្ឋាភិបាល នឹងកំណត់ដោយអនុក្រឹត្យ ។ ការលើកលែងពន្ធលើប្រាក់ចំណេញ នឹងត្រូវអនុវត្ត ចាប់ពីឆ្នាំដែលបានទទួលប្រាក់ចំណេញលើកទីមួយ ។ ការខាតបង់រយៈពេល ៥ ឆ្នាំបន្តបន្ទាប់ ត្រូវបានអនុញ្ញាតអោយ យកមកទូទាត់គិតប្រាក់ចំណេញ ។ ក្នុងករណីយកប្រាក់ចំណេញមកធ្វើវិនិយោគបន្ត ប្រាក់ចំណេញត្រូវបានអនុញ្ញាតអោយ រួចពន្ធទាំងស្រុង ។

៣- មិនយកអាករលើការបែងចែកប្រាក់ចំណេញ នៃការវិនិយោគ ទោះជាប្រាក់ទាំងនោះត្រូវផ្ទេរទៅបរទេសក្តី ឬ បែងចែកក្នុង ប្រទេសក្តី ។

៤- ការលើកលែងពន្ធគយ និងពន្ធអាករ ១០០% ក្នុងការនាំចូលសម្ភារៈសំណង់ មធ្យោបាយផលិតកម្ម គ្រឿងសម្ភារៈបរិក្ខា ទំនិញពាក់កណ្តាលសំរេច វត្ថុធាតុដើម និងគ្រឿងបន្លាស់ សំរាប់ប្រើប្រាស់ត្រូវមាន ល័ក្ខខ័ណ្ឌណាមួយ ដូចតទៅ :

  ក- ការវិនិយោគ ដែលមានទិសដៅសំរាប់បំរើអោយការនាំចេញ ក្នុងករណីអប្បបរមា ៨០% នៃផលិតផលសរុប ។

  ខ- មានទីតាំង នៅក្នុងតំបន់អភិវឌ្ឍន៍ពិសេស ដែលមានក្នុងបញ្ជីអាទិភាពសំរាប់អភិវឌ្ឍន៍ ប្រកាសដោយ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

  គ- ឧស្សាហកម្មទេសចរណ៍

  ឃ- ឧស្សាហកម្ម ប្រើប្រាស់កម្លាំងពលកម្មច្រើន ឧស្សាហកម្មកែច្នៃ កសិ-ឧស្សាហកម្ម

  ង- ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការផលិតថាមពល ។

ការលើកលែងពន្ធគយ និង ពន្ធអាករ ១០០% ខាងលើនេះ ត្រូវអនុវត្តជារៀងរហូតស្របតាមរយៈពេល ដែលកំណត់ក្នុងកិច្ចសន្យា ឬសៀវភៅបន្ទុក សំរាប់ការវិនិយោគ ដែលផលិតទំនិញនាំចេញក្នុងកំរិត អប្បបរមា ៨០% នៃផលិតកម្មសរុប ដូចមានចែងក្នុងចំណុច (៤)ក ខាងលើ និងសំរាប់ការវិនិយោគ ដែលមានទីតាំង ក្នុងតំបន់អភិវឌ្ឍន៍ពិសេស ដូចមានចែងក្នុងចំណុច (៤)ខ ។

ក្រៅពីប្រភេទការវិនិយោគ ដែលមានចែងក្នុងចំណុច (៤)ក និងចំណុច (៤)ខ ខាងលើនេះ ការលើកលែងពន្ធគយ និងពន្ធអាករ ១០០% ត្រូវបានអនុញ្ញាតអោយសំរាប់តែក្នុងរយៈពេលនៃការរៀបចំ កសាងសហគ្រាស រោងចក្រ អាគារ និងការចាប់ដំណើរការ អាជីវិកម្ម ផលិតកម្មនៅឆ្នាំដំបូង ប៉ុណ្ណោះ ។

៥- ការលើកលែងពន្ធគយ ១០០% ក្នុងការនាំចេញផលិតផលទៅក្រៅប្រទេស ។

៦- ការអនុញ្ញាតអោយយកចូលមកក្នុង ព្រះរាជាណាចក្រកម្ពុជា នូវជនបរទេសណាដែលជា :

- បុគ្គលិក និងអ្នកជំនាញការខាងគ្រប់គ្រង
- បុគ្គលិកបច្ចេកទេស

- កម្មករជំនាញ
- សហព័ន្ធ និងអ្នកក្នុងបន្ទុករបស់ខ្លួន ដែលអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហើយស្របទៅតាម ច្បាប់អន្តោប្រវេសន៍ និង ច្បាប់ការងារ ។

មាត្រា១៥:

ការអនុញ្ញាត និងការលើកទឹកចិត្តដែលបានផ្តល់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មិនអាច ផ្ទេរ ឬលក់បានឡើយ ។

## ជំពូកទី ៦: កម្មសិទ្ធិ និង ការប្រើប្រាស់ដីធ្លី

មាត្រា១៦:

អនុលោមតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងបទបញ្ញត្តិទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងកម្មសិទ្ធិ និង ការប្រើប្រាស់ដីធ្លី :

១- កម្មសិទ្ធិដីធ្លីសំរាប់បំរើអោយគោលដៅ នៃសកម្មភាពវិនិយោគ ត្រូវបានប្រគល់ជូនចំពោះអ្នកវិនិយោគ ដែលជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរ ។ នីតិបុគ្គលមានសញ្ជាតិ ជាខ្មែរ គឺជានីតិបុគ្គលដែលភាគហ៊ុនចាប់តាំងពី ៥១% ឡើងទៅ នៃដើមទុនសរុបជាកម្មសិទ្ធិនៃ រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានសញ្ជាតិជាខ្មែរ ។

២- អ្នកវិនិយោគ អាចប្រើប្រាស់ដីធ្លីតាមរយៈ ការជួលសំរាប់រយៈពេលវែងរហូតដល់ ៧០ឆ្នាំ ហើយអាចស្នើសុំជួលបន្ត។ ការប្រើប្រាស់ដីធ្លីនេះ រាប់បញ្ចូលទាំងសិទ្ធិ នៃកម្មសិទ្ធិទាំងឡាយនៅ លើផ្ទៃដីនោះ ត្រូវអនុវត្តស្របតាមច្បាប់ ។

## ជំពូកទី ៧: ការប្រើប្រាស់កំលាំងពលកម្ម

មាត្រា១៧:

អ្នកវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិធ្វើការជ្រើសរើស និង ជួលនិយោជិត ខ្មែរ និងបរទេសបានដោយសេរី ផ្អែកលើមូលដ្ឋាននៃច្បាប់ការងារ និង ច្បាប់អន្តោប្រវេសន៍ ។

មាត្រា១៨:

អ្នកវិនិយោគ ត្រូវបានអនុញ្ញាតអោយជួលនិយោជិតបរទេស ដូចមានចែងក្នុងមាត្រា ១៤ (៦) ក្នុងលក្ខ័ខ័ណ្ឌដូចតទៅ :

១- គុណភាព សមត្ថភាព និងជំនាញមិនអាចរកបាន នៅព្រះរាជាណាចក្រកម្ពុជាក្នុងចំណោមប្រជាពលរដ្ឋខ្មែរ ។ បើមានការជួលនិយោជិតប្រភេទនេះ ត្រូវភ្ជាប់មកជាមួយនូវសេចក្តីចម្លង លិខិតឆ្លងដែន សញ្ញាប័ត្រ និង ប្រវត្តិរូបសង្ខេប របស់និយោជិតនោះ ។

២- អ្នកវិនិយោគ មានកាតព្វកិច្ចធ្វើការបណ្តុះបណ្តាលជាប្រចាំ និងសមស្របជូននិយោជិតខ្មែរ ។

៣- ការជំរុញលើកកំពស់និយោជិតខ្មែរដើម្បីអាចក្លាយទៅជាអ្នកមានឋានៈខ្ពស់ត្រូវធ្វើជាប្រចាំ។

មាត្រា១៩:

និយោជិតបរទេស ត្រូវអនុញ្ញាតអោយផ្ទេរទៅក្រៅប្រទេស នូវប្រាក់បៀវត្ស ដែលទទួលបាន ក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈប្រព័ន្ធធនាគារ ក្រោយពីបានបង់ពន្ធរួចហើយ ។

## ជំពូកទី ៨: វិវាទ និង ការរំលាយ

មាត្រា២០:

វិវាទដែលទាក់ទងទៅនឹងកិច្ចការវិនិយោគ នៅក្នុងព្រះរាជាណាចក្រកម្ពុជា របស់អ្នកវិនិយោគ ដែលពាក់ព័ន្ធទៅនឹងសិទ្ធិ និងកាតព្វកិច្ចដែលមានចែងក្នុងច្បាប់នេះអាច:

១- ដោះស្រាយ ដោយសម្រុះសម្រួលតាមរយៈការពិគ្រោះគ្នា រវាងភាគីជំលោះទាំងឡាយ ។

២- ក្នុងអំឡុងពេលពីរខែ បើវិវាទមិនបានដោះស្រាយតាមការសម្រុះសម្រួលគ្នាទេ វិវាទនេះអាច:

- លើកយកមកដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ផ្តល់យោបល់
- ដោះស្រាយតាមផ្លូវតុលាការ នៃព្រះរាជាណាចក្រកម្ពុជា
- ឬដោះស្រាយតាមនីតិវិធីអន្តរជាតិណាមួយ តាមការព្រមព្រៀង នៃភាគី ។

មាត្រា២១:

ក្នុងករណីអ្នកវិនិយោគ មានបំណងចង់បញ្ចប់សកម្មភាពរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា អ្នកវិនិយោគនោះ ត្រូវជូនពតិមានទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតាមរយៈលិខិតអនុសិដ្ឋ ឬ លិខិតប្រគល់ផ្ទាល់ដៃ ដោយមានបញ្ជាក់ថាបានទទួលត្រឹមត្រូវ ។ លិខិតខាងលើនេះត្រូវចុះហត្ថលេខាដោយអ្នកវិនិយោគ ឬ អ្នកតំណាងពេញសិទ្ធិរបស់ក្រុមហ៊ុន ហើយត្រូវបញ្ជាក់អំពីមូលហេតុនៃការបញ្ចប់សកម្មភាពនោះផង ។

មាត្រា២២:

ក្នុងករណីដែលមានការសុំរំលាយក្រៅផ្លូវតុលាការ អ្នកវិនិយោគត្រូវផ្តល់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នូវលិខិតបញ្ជាក់ពីម្ចាស់បំណុល ពីអ្នកប្តឹងរបស់ខ្លួន និងពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ថាបញ្ហាទាំងឡាយ ត្រូវបានដោះស្រាយចប់ជាស្ថាពរហើយ ទើបអ្នកវិនិយោគនោះអាចត្រូវបានអនុញ្ញាតអោយរំលាយក្រុមហ៊ុន ឬសហគ្រាសរបស់ខ្លួនជាផ្លូវការបាន តាមបែបបទនៃច្បាប់ពាណិជ្ជកម្ម

មាត្រា២៣:

ក្នុងករណីដែលអ្នកវិនិយោគ ត្រូវបានអនុញ្ញាតអោយរំលាយក្រុមហ៊ុន ឬសហគ្រាសរបស់ខ្លួនជាផ្លូវការ ទោះតាមផ្លូវតុលាការក្តី ឬក្រៅផ្លូវតុលាការក្តី អ្នកវិនិយោគអាចផ្ទេរនូវទ្រព្យសម្បត្តិដែលសេសសល់ ទៅក្រៅប្រទេស ឬមួយប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ចំពោះគ្រឿងម៉ាស៊ីន និងសម្ភារៈបរិក្ខារ ដែលបានការអនុញ្ញាតអោយនាំចូលដោយរួចពន្ធ ហើយបានប្រើប្រាស់ក្នុងអំឡុងពេល តិចជាងប្រាំឆ្នាំ (៥ឆ្នាំ) អ្នកវិនិយោគត្រូវបង់ពន្ធតាមច្បាប់ជាធរមាន ។

## ជំពូកទី ៩: អវសានបញ្ញត្តិ

មាត្រា២៤:

ការវិនិយោគទាំងឡាយដែលបានទទួលការអនុញ្ញាត ក្រោមច្បាប់ស្តីពីការវិនិយោគនៅរដ្ឋកម្ពុជា និងអនុក្រឹត្យ ស្តីពីការវិនិយោគរបស់បរទេសនៅរដ្ឋកម្ពុជា ត្រូវបានទទួលផលប្រយោជន៍ និងកាតព្វកិច្ច ដូចមានចែងក្នុងច្បាប់នេះដែរ ប៉ុន្តែច្បាប់នេះ ពុំមានអានុភាពប្រតិសកម្មទេ ។

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

មាត្រា២៥:

ក្នុងករណីដែលអ្នកវិនិយោគរំលោភ ឬមិនអនុវត្តតាមលក្ខខ័ណ្ឌទាំងឡាយ ដែលបានកំណត់ ក្រុមប្រឹក្សាអភិវិឌ្ឍន៍កម្ពុជាមានសិទ្ធិអំណាច ដកហូតសិទ្ធិផ្សេងៗ និងផលប្រយោជន៍ទាំងអស់ ឬ មួយផ្នែក ដែលបានផ្តល់ជូនអ្នកវិនិយោគកន្លងមក ។

មាត្រា២៦:

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។